# ការជ្រើសរើសពី ជែហ្វ្រី អ័រ ហូឡិន « ចូរធ្វើបុណ្យនេះ ដើម្បីរំឭកពីខ្ញុំចុះ »



« ប្រសិនបើការចងចាំគឺជាករណីយកិច្ចដ៏សំខាន់ចំពោះមុខយើង នោះតើនឹងមានអ្វីផុសចេញមកក្នុងការចងចាំរបស់យើង នៅពេលដែលនំប៉័ង និងទឹកដ៏សាមញ្ញ និងមានតម្លៃទាំងនោះត្រូវបានផ្ដល់ឲ្យយើង ?

« យើងអាចចងចាំដល់ជីវិតមុនឆាកជីវិតនេះរបស់ព្រះអង្គសង្គ្រោះ និងអ្វីៗទាំងអស់ដែលយើងបានដឹងអំពីទ្រង់ ថាទ្រង់បានធ្វើការណ៍ក្នុងនាមជាព្រះយេហូវ៉ាដ៏មហិមា ព្រះដ៏បង្កបង្កើតនៃស្ថានសួគ៌ និងផែនដី និងអ្វីៗទាំងអស់ដែលនៅលើផែនដីនោះ ។ យើងអាចចងចាំថា ទោះបីជានៅក្នុងក្រុមប្រឹក្សាដ៏ធំនៃស្ថានសួគ៌ នោះទ្រង់បានស្រឡាញ់យើង និងបាននៅរឹងមាំជាខ្លាំង រហូតដល់យើងបានជោគជ័យគឺដោយសារព្រះចេស្ដានៃព្រះគ្រីស្ទ និងសេចក្ដីជំនឿរបស់យើងទៅលើព្រះលោហិតនៃកូនចៀម ( សូមមើលវិវរណៈ ១២:១០–១១ ) ។

« យើងអាចចងចាំពីភាពរុងរឿងសាមញ្ញនៃការប្រសូតមកលើផែនដីរបស់ទ្រង់ ។ . . .

« យើងអាចចងចាំពីអព្ភូតហេតុទាំងឡាយរបស់ព្រះគ្រីស្ទ និងការបង្រៀនទាំងឡាយរបស់ទ្រង់ ការព្យាបាល និងជំនួយនានារបស់ទ្រង់ ។ យើងអាចចងចាំថា ទ្រង់បានប្រោសអ្នកខ្វាក់ឲ្យមើលឃើញ និងអ្នកថ្លង់ឲ្យស្ដាប់ឮ និងអ្នកខ្វិនឲ្យដើរបាន ។ ពេលនោះ គឺនៅថ្ងៃណាដែលយើងមានអារម្មណ៍ពីដំណើរការរីកចម្រើនរបស់យើងឈប់មួយកន្លែង ឬសេចក្ដីអំណរ និងទស្សនវិស័យរបស់យើងបានទៅជាអាប់រស្មី នោះយើងអាចបោះជំហានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ។ . . .

« យើងអាចចងចាំថា ទោះបីជាមានបេសកកម្មដ៏រឹងមាំត្រូវសម្រេចឲ្យបានបែបនោះត្រូវបានប្រទានទៅឲ្យទ្រង់ក្ដី ក៏ព្រះអង្គសង្គ្រោះបានរកឃើញនូវសេចក្ដីអំណរនៅក្នុងជីវិត ទ្រង់បានរីករាយនឹងប្រជាជន និងបានប្រាប់ពួកសិស្សរបស់ទ្រង់ឲ្យរីករាយឡើង ។ ទ្រង់បានមានបន្ទូលថា យើងគួរតែរំភើបចិត្តនឹងដំណឹងល្អ ប្រៀបដូចជាមនុស្សម្នាក់ដែលបានរកឃើញទ្រព្យដ៏អស្ចារ្យមួយ មុក្ដាដ៏ពិតដ៏មានតម្លៃមហិមា នៅចំពីក្រោមជណ្ដើរឡើងផ្ទះ ។ . . .

« យើងអាចចងចាំថា ព្រះគ្រីស្ទបានហៅពួកសិស្សរបស់ទ្រង់ថាជាមិត្តភក្ដិ ។ . . .

« យើងអាច—ហើយគួរតែ—ចងចាំដល់រឿងដ៏អស្ចារ្យទាំងនេះដែលបានកើតមកក្នុងជីវិតរបស់យើង ហើយថា ‹ គ្រប់អស់ទាំងការណ៍ណាដែលល្អ នោះចេញមកពីព្រះគ្រីស្ទ › ( ម៉ូរ៉ូណៃ ៧:២៤ ) ។ . . .

« នៅថ្ងៃណាមួយ យើងនឹងមានបុព្វហេតុដើម្បីចងចាំដល់ទង្វើដ៏ឥតសណ្ដានចិត្តដែលទ្រង់បានទទួល ការបដិសេធដែលទ្រង់បានជួបប្រទះ និងភាពអយុត្តិធម៌—ឱភាពអយុត្តិធម៌— នោះទ្រង់បានស៊ូទ្រាំ ។ ដូចគ្នាដែរ នៅពេលដែលយើងនឹងជួបជីវិតបែបនោះខ្លះនៅថ្ងៃណាមួយ នោះយើងអាចចងចាំថា ព្រះគ្រីស្ទដ៏បានជួបបញ្ហាពីគ្រប់ជ្រុងជ្រោយដែរ ប៉ុន្តែទ្រង់មិនបានទ័លផ្លូវឡើយ មានសេចក្ដីវិលវល់ តែមិនទ័លគំនិតទេ មានគេធ្វើទុក្ខ តែមិនមែនត្រូវបោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្តូក តែមិនស្លាប់ទេ » ( សូមមើល កូរិនថូសទី ២ ៤:៨–៩) ។

« នៅពេលគ្រាលំបាកទាំងនោះដើរមកកាន់យើង នោះយើងអាចចងចាំថា ព្រះយេស៊ូវបានយាងចុះក្រោមគ្រប់ទាំងអស់ មុនពេលទ្រង់បានយាងឡើងទៅស្ថានខ្ពស់ ហើយថាទ្រង់បានរងការឈឺចាប់ និងទុក្ខវេទនា និងការល្បួងគ្រប់បែបយ៉ាង ដើម្បីឲ្យព្រះហឫទ័យទ្រង់ពោរពេញទៅដោយសេចក្ដីមេត្តាករុណា និងដើម្បីទ្រង់អាចដឹងថាតើត្រូវជួយរាស្ត្រទ្រង់បែបណាតាមជំងឺរបស់គេ ( សូមមើល គ និង ស ៨៨:៦; អាលម៉ា ៧:១១–១២ ) ។

« ចំពោះអស់អ្នកណាដើរទ្រេតទ្រោត ឬជំពប់ជើងដួល នោះទ្រង់នឹងនៅទីនោះដើម្បីធ្វើឲ្យមានតុល្យភាព និងពង្រឹងយើងឡើង ។ នៅទីបញ្ចប់ ទ្រង់នៅទីនោះដើម្បីសង្គ្រោះយើង ហើយសម្រាប់ការណ៍ទាំងអស់នេះ នោះទ្រង់បានថ្វាយព្រះជន្មរបស់ទ្រង់ ។ . . .

« . . . អ្វីទាំងអស់នេះ យើងអាចចងចាំនៅពេលយើងត្រូវបានអញ្ជើញ ដោយសង្ឃវ័យក្មេងដែលលុតជង្គង់ចុះសុំឲ្យចងចាំដល់ព្រះគ្រីស្ទជានិច្ច » (*Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៦៧–៦៩ ) ។

© 2015 ដោយ Intellectual Reserve Inc. រក្សាសិទ្ធិគ្រប់យ៉ាង